អង្គរបុរី
សម្លេងខ្មែរនៅបរទេស

# ស្ដេចក្រោយសីហនុ

ដោយ លី-ឌៀប ★ ថ្ងៃទី៣០ វិច្ឆិកា ២០០៣



បើគិតឲ្យជ្រៅ តើអ្វីដែលជាបុព្វហេតុនៃការរលាយរលត់រាជានិយម នៅស្រុកខ្មែរ ? គឺស្ដេចសីហនុខ្លួនឯងតែម្ដង ដែលជាបុព្វហេតុធំបង្អស់ និងមុនគេបំផុត ។ គឺព្រោះតែចិត្តលោភលន់អំណាចនិងលោភកិត្តិយស ហួសហេតុផង របស់ស្ដេចសីហនុនោះហើយ បានជាស្ដេចសីហនុដើរតួរជាស្ដេចផង ហើយជាមេចាត់ចែងនយោបាយខ្មែរផង (អាថ្វាកណ្ដាល គេមិនដែលបញ្ចេញយោបល់ថាត្រូវលើកហ៊ុន-សែន ឲ្យធ្វើជានាយករដ្ឋមន្ត្រីសំរាប់នីតិកាលទី៣ មុនអ្វីៗកើតឡើងដូច្នេះទេ) ។

ព្រឹត្តិការណ៍ថ្ងៃទី១៨ មិនា ១៩៧០ ពុំមែនជា<ការកំចាត់ឬការរំលាយចោល>នូវរបបរាជានិយមដូចដែលស្ដេចសីហនុនិងពួកហែរហមស្រែកឆោឡោនោះទេ តាមពិតទៅសភាខ្មែរទាំងពីរបានទម្លាក់ស្ដេចសីហនុចេ-ញពី <តំណែងប្រមុខរដ្ឋ> ប៉ុណ្ណោះ (ពុំមែនទម្លាក់ស្ដេចសីហនុចេញពីព្រះរាជបល្ល័ង្កនោះឡើយ) ។

នេះគឺជាមេរៀនប្រវត្តិសាស្ត្រក្ដៅៗប្រាប់ឲ្យដឹងច្បាស់ថា ការវិនាសស្លាប់នៃរាជានិយមនោះ វាបណ្ដាលមកពីមនុស្សរាជានិយម ដែលបានទាត់ចោលខ្លួនឯងនូវ ការធានាដល់និរន្តភាព (la continuité) នៃរាជានិ-យមនោះតែម្ដង ជាពិសេសគឺស្ដេចសីហនុ (!!)

ទោះជារដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ ទទួលស្គាល់និងធានាចំពោះវត្តមាននៃស្ដេចស្រុកខ្មែរក៏ដោយ ក៏សីហនុគ្មានចង់ឲ្យនរណាសោយរាជ្យទេក្រៅពីឈ្មោះសីហនុ ហើយកែខៃមាត្រារដ្ឋធម្មនុញ្ញ មិនអាចឲ្យមានស្ដេចសោ-យរាជ្យជាបន្តនៅពេលរាជបល្ល័ង្កទំនេរនោះទេ ។ ដូច្នេះគេអាចប៉ាន់ស្រេចជាមុនថា ផុតពីសីហនុភ្លាម គឺការកាប់ចាក់រវាងស្ដេចនានា ដើម្បីឡើងសោយរាជ្យ ។

❑

ចំនួនជាង៣ទសវត្សក្រោយមក...

ថ្មីៗនេះ, ស្ដេចសីហនុខំប្រឹងបង្វិលព្រឹត្តិការណ៍នយោបាយជាតិ ពីខ្មៅទៅស ឬពីសទៅខ្មៅ ដើម្បីព្រះអង្គឆ្លៀតយកប្រៀបអូសទាញបញ្ហា <ស្ដេចស្នងរាជ្យ>មកធ្វើជាថ្នូរសំរាប់ដូរគ្នា ។ បើព្រះអង្គអាចធ្វើឲ្យសំរេចនូវនយោបាយរបស់ចិន-យួន ដែលចង់បានហ៊ុន-សែនបន្តកាន់ក្ដាប់អំ-ណាចក្នុងរដ្ឋាភិបាលនីតិកាលទី៣មែននោះ ជាការតបវិញ ព្រះអង្គចង់ឲ្យគ្រប់ៗគ្នាសុខចិត្តឲ្យព្រះអង្គបានសំរេចសមតាមព្រះរាជហឫទ័យ ។

ដូចគេដឹងស្រាប់រួចមកហើយ, ស្ដេចសីហនុមានបញ្ហា<ស្ដេចស្នងរាជ្យ> តាំងយូរមកម្ល៉េះ ។ មូលហេតុគឺមកពីព្រះអង្គមានប្រពន្ធច្រើនពេកនិងពងចោលនៅពាសទីកន្លែង ។ ព្រះរាជបុត្រាដែលព្រះអង្គពេញចិត្តជាងគេ គឺព្រះអង្គម្ចាស់នរោត្ដម-នរ៉ាទីប៉ូ ។ ព្រះអង្គចង់បានកូននេះ ឡើងកាន់តំណែងជាប្រមុខរដ្ឋ (ស្ដេចសីហនុថ្លែងអំពីរឿងនេះ នៅពេលព្រះអង្គជាប្រមុខរដ្ឋ) ។ ជាអកុសល, ព្រះអង្គម្ចាស់នរ៉ាទីប៉ូ ជនចិនកុម្មុយនិស្តនិយមរូបនេះ ក៏ត្រូវស្លាប់នៅក្នុងជំនាន់ខ្មែរក្រហមទៅ ។ ដល់ដូច្នេះទៅ នៅក្នុងចំណោមប្អូន កូន និងក្មួយ ស្ដេចសីហនុហាក់ដូចជាមិនពេ-ញចិត្តនឹងអង្គមួយណាសោះ ។ ការជ្រើសរើសទី២ ប្រហែលព្រះអង្គម្ចាស់នរោត្ដម-សីហមុនី ដែលត្រូវជាកូនរបស់ព្រះអង្គជាមួយអ្នកម្នាងម៉ូនិ-ក ។ ក៏ប៉ុន្តែ ព្រះអង្គម្ចាស់សីហមុនីបានទូលតបព្រះអង្គជាច្រើនដងរួចមកហើយថា ទ្រង់មិនចង់ស្នងរាជ្យបន្តទេ ហើយសុខចិត្តលើកព្រះរាជបល្ល័ង្កថ្វាយទៅព្រះអង្គម្ចាស់នរោត្ដម-រណឫទ្ធិ ដែលត្រូវជាកូនប្រុសប្រពន្ធទី១របស់ស្ដេចសីហនុជាមួយអ្នកម្នាង ផាត់-កាញ៉ុល (អ្នកម្នាងផាត-កាញ៉ុលក្រោយមក បានទៅរៀបការជាមួយលោកចាប-ហួត បានកូនប្រុសមួយទៀត ឈ្មោះចាប-ញ៉ាលីវុធ) ។

ស្ដេចសីហនុមិនសព្វព្រះទ័យជាមួយទ្រង់រណឫទ្ធិប៉ុន្មានឡើយ តែការប្រគល់រាជ្យថ្វាយទៅព្រះអង្គម្ចាស់នេះ ក៏មុខជាបង្កឲ្យមានសង្គ្រាមជាមួយព្រះអង្គម្ចាស់មួយចំនួនទៀតពុំខាន ។ ដូច្នេះដំណោះស្រាយមានតែមួយគត់ គឺលើកប្រពន្ធចុងទី៦របស់ខ្លួន គឺអ្នកម្នាង Paule Monique Izzi ឲ្យឡើងស្នងរាជ្យបន្ត ឬឲ្យឡើងធ្វើជានិមិត្តរូបរបបរាជានិយម ជំនួសខ្មោចព្រះមាតារបស់ព្រះអង្គ ព្រះមហាក្សត្រីយានីស៊ីសុវត្ថិ-កុសមៈនារីរ័ត្ន ។

ព្រះអង្គបានលើកឡើងនូវលេសគ្រប់បែបយ៉ាង ព្រមទាំងដំអែដំអូ-ញទួញទុក្ខថា ព្រះអង្គមានព្រះជន្មាយុ៨២ព្រះវស្សាហើយ មិនដឹងស្លាប់ថ្ងៃណាទេ... សភាក៏គ្មាន រដ្ឋាភិបាលក៏មិនដឹងកើតពេលណា ក្រុមប្រឹក្សាព្រះរាជបល្ល័ង្កក៏ដឹងជានរណាខ្លះ ហើយច្បាប់ស្ដេចស្នងរាជ្យក៏ពុំបានធ្វើនៅឡើយ ÷ បើដូច្នេះ... បើអត់ពីព្រះអង្គទៅ សម្ដេចជា-ស៊ីមនឹងឡើងជាប្រមុខរដ្ឋស្ដីទី រួចហើយមហាក្សត្រីមុនីនាថនឹងទៅជា «និមិត្តរូបរបបរាជានិយមខ្មែរ» ។ ចំណុចនេះស្ដេចសីហនុចង់មានន័យថា ÷ បើចិន-យួនបានដូចបំណង, សម្ដេចហ៊ុន-សែននឹងបានធ្វើជានាយករដ្ឋមន្ត្រី, សម្ដេចជា-ស៊ីមបានធ្វើជាប្រមុខរដ្ឋស្ដីទី... ព្រះអង្គគ្រាន់តែសុំម៉ូនិកបន្តរាជ្យតែមួយប៉ុណ្ណឹង... មិនបានទេឬ (??) ។

❑

រឿងដែលស្ដេចសីហនុមិនខ្វល់អំពល់នោះ គឺប្រជារាស្ត្រខ្មែរ ។ ព្រះអង្គអត់«ម៉ុងហ្វូ»ទេ ដល់កាលណាអត់ពីព្រះអង្គទៅ ។ ទោះអាណាប្រជានុរាស្ត្រចូលចិត្តនឹងប្រពន្ធចុងរបស់ព្រះអង្គក្ដី ឬមួយមិនពេញចិត្តក្ដី ។ ព្រះអង្គមានចិន មានយួន មានសម្ដេចហ៊ុន-សែន មានសម្ដេចជា-ស៊ីម ជួយការពារប្រពន្ធចុងនេះរួចទៅហើយ ។ រដ្ឋធម្មនុញ្ញជាច្បាប់គេបង្កើតបានទេតើ ដូចគេលើកព្រះអង្គឲ្យឡើងសោយរាជ្យជាលើកទី២ទៀតអីចឹង សូម្បីតែត្រូវក្បត់នឹងពាក្យសច្ចារបស់ខ្លួនកាលពីឆ្នាំ១៩៥៥ ដែលថាមិ

នត្រឡប់មកកាន់រាជបល្ល័ង្កវិញដាច់ខាតក៏ដោយ ក៏គេនៅតែលើកថ្វាយព្រះអង្គដដែល (ស្តេចសីហនុបានរាជបល្ល័ង្កមកវិញ ក៏ដោយសារផ្ទូរជាមួយចិន-ឃួន និងបក្សប្រជាជនកម្ពុជា យល់ព្រមឲ្យហ៊ុន-សែនធ្វើជានាយករដ្ឋមន្ត្រីទី២ និងយល់ព្រមឲ្យបក្សប្រជាជនកម្ពុជាក្តាប់អំណាចជាងពាក់កណ្តាលជាមួយគណបក្សហ៊្វុនស៊ិនប៉ិច) ។

នៅក្រោយរដ្ឋប្រហារឆ្នាំ១៩៩៧, តើពុំមែនស្តេចសីហនុទេឬ ដែលប្រហេបត្រហបកាន់ជើងហ៊ុន-សែននិងគណបក្សប្រជាជនកម្ពុជា រួចវាយប្រហារទៅលើកូនបង្កើតខ្លួនឯង ? ។ នរណាៗក៏យល់ដែរ អំពីអាកប្បកិរិយារបស់ស្តេចសីហនុនេះ ! រួចបន្ទាប់មកព្រះអង្គក៏បង្ខំទ្រង់រណឫទ្ធិ ឲ្យបែងចែកអំណាចគ្នាជាមួយហ៊ុន-សែនជាលើកទី២ ។

ឧបមាថា នៅលើកនេះ ស្តេចសីហនុបានសំរេចព្រះបំណាង លើកព្រះអង្គម្ចាស់នរោត្តម-សីហមុនី ឬលើកប្រពន្ធចុងម៉ូនិករបស់ព្រះអង្គឲ្យឡើងសោយរាជ្យ... តើហេតុការណ៍នឹងទៅជាយ៉ាងណា ? ។

ដូចយើងបានជំរាបមិត្តអ្នកអានជាច្រើនដងរួចមកហើយថា ស្តេចស្នងបន្តរាជ្យក្រោយពីសីហនុ មុខជានឹងមាន<បញ្ហា>ទាំងអស់ ។ មូលហេតុដែលយើងនិយាយដូច្នេះ ពីព្រោះសូម្បីតែស្តេចសីហនុគង់នៅជ្រងោៗ មានពួកមេខ្មែរខ្លះប្រមាថមើលងាយទៅហើយ (ហ៊ុន-សែនធ្លាប់និយាយថា ខ្លួនមិនចង់ធ្វើស្តេចទេ តែចង់ធ្វើជាអ្នកបង្កើតស្តេច ! ចំណែករណឫទ្ធិនិងសម-រង្ស៊ីវិញ នាពេលថ្មីៗនេះ មិនទាំងទៅសុំសួរយោបល់ព្រះមហាក្សត្រដែលកំពុងគង់រង់ចាំនៅក្នុងស្រុកទេ តែនាំគ្នាធ្វើដំណើរចេញក្រៅស្រុក សុំការគាំទ្រពីរដ្ឋាភិបាលបរទេសទៅវិញ ។ ទាំងអស់នោះគឺជាការប្រមាថមើលងាយដល់ស្តេចសីហនុខ្លាំងណាស់ !)...ចុះទំរាំអត់ពីព្រះអង្គទៅ តើឲ្យគេនាំគ្នានៅគោរព<លត់ក្រាប> កូននិងប្រពន្ធចុងរបស់ព្រះទៀតដែរឬទេ ? ជាពិសេសទ្រង់រណឫទ្ធិ (!!)

យើងជឿថា ស្តេចសីហនុចង់ធ្វើ<បាប>កូននិងប្រពន្ធចុងចៀសជាងជួយលើកឲ្យខ្ពង់ខ្ពស់ (!!) ។ ហើយជាមួយគ្នានេះដែរ បើគណបក្សរាជានិយមហ៊្វុនស៊ិនប៉ិចរំលាយខ្លួនចូលគ្នាជាមួយគណបក្សសម-រង្ស៊ីដូចការសន្យារបស់ទ្រង់រណឫទ្ធិមែន នោះគេប្រហែលនឹងឃើញ«របបសាធារណរដ្ឋទី២» ចាប់បដិសន្ធិឡើងទេដឹង (??) ។

★ ព្រះមហាក្សត្រស្លាប់ហើយ ! ជយោព្រះមហាក្សត្រ (!!)

អង្គរបុរី
សម្លេងខ្មែរនៅបរទេស

# អ្នកម្នាងម៉ូនិចនឹងក្លាយទៅជា និមិត្តរូបអនាគតនៃរបបរាជានិយមខ្មែរឬ?

ដោយ លី-ឌៀប ★ ថ្ងៃទី១៦ វិច្ឆិកា ២០០៣

នៅស្រុកខ្មែរ អ្វីៗសុទ្ធតែប្លែកចម្លែកអស្ចារ្យ សូម្បីតែការជ្រើសរើសស្តេចស្នងរាជ្យបន្តពីស្តេចសីហនុទៅ ក៏ប្លែកមិនដែលឃើញពីមុនមកដែរ ។



Miss Paule Monique IZZI
ភរិយាទី៦របស់ស្តេចនរោត្តម-សីហនុ

មាត្រាទី១០នៃរដ្ឋធម្មនុញ្ញរាជាណាចក្រកម្ពុជាទី២ចែងថា ៖ «របបរាជានិ-យមកម្ពុជា ជារបបជ្រើសតាំង ។ ព្រះមហាក្សត្រទ្រង់<ឥតមាន>ព្រះរាជអំណាចចាត់តាំងព្រះរជ្ជទាយាទ សំរាប់គ្រង់សម្បត្តិឡើយ» ។

មាត្រាទី១២ចែងថា ៖ «នៅពេលព្រះមហាក្សត្រទ្រង់ចូលទីវង្គត ប្រធានរដ្ឋសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីក្នុងឋានៈជាព្រះរាជានុសិទ្ធិនៃព្រះរាជា-ណាចក្រកម្ពុជា» ។

មាត្រាទី១៤នៃរដ្ឋធម្មនុញ្ញបានចែងថា ៖ «ត្រូវបានជ្រើសរើសជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា សមាជិកនៃព្រះរាជវង្សានុវង្សខ្មែរ ដែលមានព្រះជន្មាយុយ៉ាងតិច៣០ព្រះវស្សា ហើយដែលជាព្រះរាជបច្ឆាញាតិនៃព្រះមហាក្សត្រអង្គដួង ឬព្រះមហាក្សត្រនរោត្តម ឬក៏ព្រះមហាក្សត្រស៊ីសុវត្ថិ ។ មុនចូលគ្រង់រាជស-ម្បត្តិ ព្រះមហាក្សត្រទ្រង់ថ្លែងសច្ចាប្រណិធាន ដូចមានចែងក្នុងឧបសម្ពន្ធទី៤» ។

❑

★★ មិនខ្វល់ធ្វើតាមមាត្រាខាងលើនេះ និងបើយោងតាម<រាជសារ>របស់ស្តេចសីហនុដែលយើងបានចុះនៅខាងក្រោម យើងសង្កេតឃើញស្តេចសីហនុកំពុងបន្ថែមទម្ងន់ឲ្យធ្ងន់ថែមទៀត ទៅលើ<វិបត្តិនយោបាយខ្មែរបច្ចុប្បន្ន> និងចង់ឆ្លៀតឱកាសពេល<សភានិងរដ្ឋាភិបាលខ្មែរ>កំពុងរាំងស្ទះមិនទាន់ប្រសូត្តចេញជារូបរាងនៅឡើយនេះ ដើម្បីសំរេចនូវវត្ថុបំណងរបស់ព្រះអង្គ ដែលបានគុំទុកជាយូរមកហើយនោះ គឺលើអ្នកម្នាង<ម៉ូនិច>ឲ្យស្មើឋានៈម្តាយរបស់ខ្លួន ធ្វើជា<រាជានុសិទ្ធិ>បន្តពីព្រះអង្គទៅ និងធ្វើជា<អនាគតនិមិត្តរូបនៃរបបរាជានិយមខ្មែរ> ។

សំនួររបស់យើងសួរថា ៖ បើពួកមេៗខ្មែរចង់ធ្វើអ្វីស្រេចចិត្ត បំពានលើច្បាប់ ឬគិតតែពី<កែច្បាប់>ដើម្បីសំរួលតាមការត្រេកត្រអាលចង់បានរបស់ខ្លួនយ៉ាងនេះ តើអនាគតស្រុកខ្មែរនឹងក្លាយជាយ៉ាងណាទៅ ?

នៅក្រោយប្រជុំកំពូលថ្ងៃទី៥ វិច្ឆិកា ២០០៣, យើងឃើញស្តេចសីហនុមានអាការៈអន្ទះសារយ៉ាងខ្លាំង ខំបញ្ចេញនូវ<រាជសារ>និងអត្ថបទផ្សេងៗគ្នា ព្រមទាំងកៀងពួកមេគណបក្សនយោបាយខ្មែរដែលឈ្នះឆ្នោត ឲ្យប្រញាប់ប្រញាល់ចូលរួមបង្កើតសភានិងរដ្ឋាភិបាល ។ ព្រះរាជកាយវិការនិងព្រះរាជបន្ទូលទាំងអស់នោះ ហាក់ដូចជាធ្វើការបង្ខិតបង្ខំទៅលើ<សម្ព័ន្ធភាពអ្នកប្រជាធិបតេយ្យ> ហើយងាកទៅយកចិត្តខាងគណបក្សប្រជាជនកម្ពុជា ក្នុងលក្ខណៈ<តថ្លៃទូទាត់ដូររបស់គ្នាទៅវិញទៅមក> (សូមអានអត្ថបទ<អង្គរបុរី>ក្រោមចំណងជើងថា ៖ «ឯងអេះខ្ញងអញ-អញអេះខ្នងឯង») ។ របស់ដែលស្តេចសីហនុចង់ដូរគ្នាជាមួយលោកហ៊ុន-សែននិងគណបក្សប្រជាជនកម្ពុជានោះគឺ បើព្រះអង្គជួយលោកហ៊ុន-សែនឲ្យឡើងធ្វើជានាយករដ្ឋមន្ត្រី... លោកហ៊ុន-សែននឹងត្រូវសុខចិត្តលើក<ប្រពន្ធចុងទី៦>របស់ព្រះអង្គ ឲ្យឡើងសោយរាជ្យបន្ត (សូមបញ្ជាក់ថា នៅក្នុងចំណោមសមាជិកក្រុមប្រឹក្សារាជសម្បត្តិទាំង៩នាក់ គណបក្សប្រជាជនកម្ពុជាមានសម្លេងច្រើនជាងគេ) ជាសំណងមកវិញ ។

ព្រះរាជសារថ្ងៃទី១១ វិច្ឆិកា ២០០៣, ស្តេចសីហនុសុំឲ្យគេធ្វើច្បាប់បោះឆ្នោតជ្រើសរើសស្តេចស្នងរាជ្យ ឲ្យមានលក្ខណៈយ៉ាងងាយបំផុត គឺ៥សម្លេងទល់នឹង៤ចាត់ទុកជាបានការ ។ ការធ្វើច្បាប់យ៉ាងដូច្នេះ ស្តេចសីហនុចង់ឲ្យប្រាកដថា លោកហ៊ុន-សែននិងគណបក្សប្រជាជនគ្រាន់តែ<អូខេ>ទៅ វាចប់បាត់ទៅហើយ ដោយគ្មានបញ្ហាអ្វីមករាំងស្ទះសោះឡើយ ពោលទោះបីទ្រង់រណឫទ្ធិដែលនឹងប្រហែលធ្វើជា<ប្រធានសភា> ចង់បោះជំទាស់ដូចម្តេចក្តី ក៏ពុំអាចប្រឆាំងបានដែរ ។ ការប្រកាសលោកជា-ស៊ីមឲ្យធ្វើជា<ប្រមុខរដ្ឋស្តីទី> នៅក្នុងពេលអវត្តមានរបស់ព្រះអង្គ គឺជាល្បិចមួយទៀតរបស់ស្តេចសីហនុ ដើម្បីច្រានទ្រង់រណឫទ្ធិឲ្យចេញនៅឆ្ងាយពី<ម្តាយចុង> ឬឲ្យចៀសចេញពីមាត់ជណ្តើររាជបល្ល័ង្ក សូម្បីតែនៅក្បែរក៏មិនអនុញ្ញាតឲ្យដែរ ។

សូមអញ្ជើញអានរាជសាររបស់ស្តេចសីហនុ ៖

## រាជសារព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ផ្ញើថ្វាយព្រះសង្ឃ និងជនរួមជាតិគ្រប់រូបជាទីគោរព និងស្រឡាញ់ដ៏ជ្រាលជ្រៅជាទីបំផុត

ភ្នំពេញ, ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៣

សូមក្រាបថ្វាយបង្គំសម្តេចព្រះសង្ឃរាជទាំងពីរព្រះអង្គ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

សូមក្រាបថ្វាយបង្គំព្រះសង្ឃជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

សូមគោរពជនរួមជាតិ បងប្អូន កូនចៅ ចៅទួត ទាំងក្នុងប្រទេស និងក្រៅប្រ-ទេស ជាទីស្រឡាញ់ដ៏ជ្រាលជ្រៅជាទីបំផុត

ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំមានហឫទ័យទុក្ខព្រួយកាន់តែខ្លាំងឡើងៗ ពីមួយថ្ងៃទៅមួយថ្ងៃ ដោយឃើញថារដ្ឋសភាថ្មីដែលប្រជារាស្ត្រលោកបានបោះឆ្នោតនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៣ ជូនអំណាចសព្វគ្រប់ដល់គណបក្សប្រជាជនកម្ពុជា គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សសម-រង្ស៊ី សំរាប់ដឹកនាំការពារកសាងរាជាណាចក្រកម្ពុជាទី២ ក៏តែងតាំងធ្វើការតាមបទបញ្ញត្តិរដ្ឋធម្មនុញ្ញពុំកើត ទោះបីសមាជិក សមាជិកាដ៏ឧត្តុងឧត្តមចំនួន១២៣រូបនៃរដ្ឋសភាជាតិនីតិកាលទី៣ លោកបានធ្វើសច្ចាប្រណិធានដ៏ឱឡារិកនៅប្រាសាទទេវាវិនិច្ឆ័យនាថ្ងៃសៅរ៍ទី៤ ខែតុលា ឆ្នាំ២០០៣ ក្រោមអធិបតីភាពនៃទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំ និងសម្តេចព្រះសង្ឃរាជទាំងពីរគណៈ ។ ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំក៏បានរៀបចំពិធីលៀងសាយភត្តជាកិត្តិយសនៅថ្ងៃនោះ ជូនអ្នកតំណាងរាស្ត្រទាំង១២៣រូប (មកពីគណបក្សប្រជាជនកម្ពុជា គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សសម-រង្ស៊ី) ។

ការដែលជជែកត្រូវធ្វើការជាមួយគ្នាឲ្យមានរដ្ឋសភាថ្មី និងរាជរដ្ឋាភិបាលថ្មីតាមរដ្ឋធម្មនុញ្ញ ច្បាប់ទម្លាប់លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស គឺគ្មានបានលទ្ធផលអ្វីសោះ ដោយសារគណបក្សហ៊្វុនស៊ិនប៉ិចនិងគណបក្សសម-រង្ស៊ី ដាក់លក្ខខណ្ឌជាច្រើនលើគណបក្សប្រជាជនកម្ពុជាមុននឹងរាជរដ្ឋាភិបាលនិងរដ្ឋសភាដំណើរការបាន។

សហគមន៍អន្តរជាតិ គណៈប្រតិភូប្រទេសធំៗនានាដែលបានអញ្ជើញមកគា-ល់ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំគេបានសំដែងនូវការព្រួយបារម្ភចំពោះវិបត្តិន

យោបាយដោះស្រាយមិនរួចនាបច្ចុប្បន្នកាលនេះ ។ គេបានស្នើទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំគិតគួរធ្វើយ៉ាងណាឲ្យមានស្ថិរភាពនយោបាយ ប្រជារាស្ត្រលោករស់នៅសុខសាន្តសូមឲ្យមានរដ្ឋសភាថ្មី និងរាជរដ្ឋាភិបាលថ្មីត្រឹមត្រូវតាមច្បាប់រដ្ឋធម្មនុញ្ញ ។

រាជាណាចក្រកម្ពុជា ជារដ្ឋឯករាជ្យដែលចាំបាច់ត្រូវមានរាជរដ្ឋាភិបាល ។ វិបត្តិនយោបាយនឹងស្រាយពុំរួចដោយគណបក្សហ្វ៊ុនស៊ិនប៉ិច គណបក្សសម-រង្ស៊ី មិនចុះសំរុងជាមួយគណបក្សប្រជាជនកម្ពុជា ហើយរាជរដ្ឋាភិបាលចាស់ដែលត្រូវបញ្ចប់អាណត្តិរបស់ខ្លួននោះ ចេះតែនៅបន្តតទៅទៀតពី១ឆ្នាំទៅ១ឆ្នាំ បើការពិភាក្សាគ្នាពុំបានសំរេចរហូតដល់ការបោះឆ្នោតសកលជាថ្មីនៅឆ្នាំ២០០៨ ហើយដែលនឹងបន្តរបៀបនេះតទៅទៀត ។ ការនេះនាំឲ្យប្រជាជាតិយើងអាម៉ាស់អាប់ឱនកិត្តិយសកិត្តិនាម ហើយធ្វើឲ្យប្រជារាស្ត្រលោករងទុក្ខវេទនាទៅតាមហ្នឹងដែរ ។ ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំក្នុងឋានៈជាមហាក្សត្រ ពុំមានសិទ្ធិអំណាចអ្វីទេ មានតែប្រជារាស្ត្រទេដែលលោកជាម្ចាស់វាសនាជាតិ មានអធិបតេយ្យពេញបរិបូរណ៍ លោកអាចដឹកនាំជួយពន្យល់គណបក្សធំៗទាំងបីកុំឲ្យធ្វើខុសពីប្រទេសនានានៅលើសកលលោក ឲ្យមានរដ្ឋសភាថ្មីកើតចេញពីការបោះឆ្នោតជាសកល ដែលជាតិនិងអន្តរជាតិគេទទួលស្គាល់ថាត្រឹមត្រូវ ឲ្យចាប់ផ្តើមធ្វើការងារបំរើប្រជារាស្ត្រ ។

បញ្ហាធំមួយទៀតដែលទាក់ទងនឹងអាយុជីវិតប្រជាជាតិយើងគឺ របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ។ សម្តេចហ៊ុន-សែនបានមានប្រសាសន៍ថា ៖ មិនត្រូវបំបាត់ចោលនូវរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ គឺរក្សាដូចមហាប្រទេសចក្រភពអង់គ្លេស មហាប្រទេសជប៉ុន រាជាណាចក្រថៃជាដើម ។

ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំសូមអរព្រះគុណព្រះសង្ឃ ជនរួមជាតិ បងប្អូន កូនចៅ ចៅទួតដែលព្រះមេត្តា មេត្តាមានហឫទ័យស្រឡាញ់រាប់អាន ទុកចិត្តចំពោះទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំដែលមានជន្មាយុ៨២វស្សាហើយ ។ ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម ព្រះសុរាម្រឹត ព្រះបិតាទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំលោកមានព្រះជន្ម៦៨ព្រះវស្សា ។ ចំណែកព្រះករុណា ព្រះបាទព្រះមុនីវង្ស ជីតាទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំមានព្រះជន្ម៦៤ព្រះវស្សា ។ ឥឡូវនេះ តើមហាក្សត្រ នរោត្តម-សីហនុ ដែលមានជន្មាយុ៨២វស្សាហើយ តើអាចមានជន្មាយុបានប៉ុន្មានឆ្នាំ ប៉ុន្មានខែ ប៉ុន្មានសប្តាហ៍ ប៉ុន្មានថ្ងៃតទៅមុខទៀត ? បច្ចុប្បន្នកាលនេះ រាជាណាចក្រកម្ពុជាពុំទាន់មានរដ្ឋសភា រាជរដ្ឋាភិបាលថ្មីជាហេតុនាំឲ្យសមាសភាពនៃក្រុមប្រឹក្សារាជសម្បត្តិ (ប្រធានព្រឹទ្ធសភា-ប្រធានរដ្ឋសភា-នាយករដ្ឋមន្ត្រី-សម្តេចព្រះសង្ឃរាជទាំងពីរគណៈ-អនុប្រធានទី១ និងអនុប្រធានទី២នៃព្រឹទ្ធសភា-អនុប្រធានទី១ និងអនុប្រធានទី២នៃរដ្ឋសភា) ពុំមានគ្រប់ចំនួនដែលបានចែងក្នុងរដ្ឋធម្មនុញ្ញនៃរាជាណាចក្រកម្ពុជា ដើម្បីធ្វើការជ្រើសរើសមហាក្សត្រថ្មី ។ ឧបមាថាមហាក្សត្រនរោត្តម-សីហនុចូលទីវង្គត់ យើងគ្មានអង្គការស្របច្បាប់ ពោលគឺក្រុមប្រឹក្សារាសម្បត្តិសំរាប់ជ្រើសរើសមហាក្សត្រថ្មី ដែលផ្ទុយពីសំណូមពររបស់សម្តេចហ៊ុន-សែន គាំទ្ររបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ដែលមានតែនៅលើក្រដាស ។ បើគ្មានមហាក្សត្រ ប្រទេសជាតិនឹងក្លាយទៅជាសាធារណរដ្ឋជាថ្មីឡើងវិញ ។ ឥស្សរជនធំៗតួយ៉ាងដូចឯកឧត្តមបណ្ឌិតឡៅ-ម៉ុងហៃ ដែលជាអ្នកមានគតម្លៃខាងសីលធម៌ ធ្លាប់ប្រឆាំងនឹងនរោត្តម-សីហនុ គាំទ្រសាធារណរដ្ឋខ្មែរមានមតិថា គួររក្សាទុកឲ្យនៅគង់វង្សតទៅទៀតរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ដែលជារបបល្អប្រពៃជាងរបបសាធារណរដ្ឋបន្តបន្ទាប់ ដែលកើតមានក្រោយរដ្ឋប្រហារនៃលោកលន់ណុល-សិរិមតៈ (ក្នុងចំណោមរបបសាធារណរដ្ឋដែលប្រទេសជាតិយើងបានពើបប្រទះ របបសាធារណរដ្ឋប៉ុល-ពតធ្ងន់ជាងគេ) ។

តើត្រូវធ្វើដូចម្តេចដើម្បីថែរក្សារបបរាជានិយមនេះ ?

តាមរដ្ឋធម្មនុញ្ញ បើមហាក្សត្រមិនគង់នៅក្នុងប្រទេស សម្តេចជា-ស៊ីមធ្វើជាប្រមុខរដ្ឋស្តីទីជំនួសមហាក្សត្រ ។

តាមយោបល់ដ៏ស្ចួចស្តើងនៃទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំគួរយើងធ្វើតាមសាធារណរដ្ឋប្រជាធិបតេយ្យកូរ៉េ ។ គេស្រឡាញ់ឯកឧត្តមមហាសេនាប្រមុខគិម-អ៊ិលសុងជាទីបំផុត ។ លោកជាបិតាឯករាជ្យ បិតារំដោះជាតិ បិតាស្ថាបនានៃការលូតលាស់គ្រប់វិស័យ ។ លោកសុគតទៅ បុត្រលោកមិនហ៊ានជំនួសបិតាលោកពេញលក្ខណៈទេ ។ ប្រជាជនកូរ៉េទុកឯកឧត្តម មហាសេនាប្រមុខ គិម-អ៊ិលសុងនៅរស់ជាអមតៈ ។ កម្ពុជាយើងបើគ្មានរដ្ឋសភាថ្មី រាជរដ្ឋាភិបាលថ្មីគួរធ្វើតាមសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ ដោយទុកមហាក្សត្រនរោត្តម-សីហនុ ដែលសុគតនៅមានជន្មាយុ តែបំពេញភារកិច្ចពុំកើត ដូច្នេះជូនសម្តេចជា-ស៊ីមទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី បំពេញភារកិច្ចជាបន្តទៀត ។

តើនរណាជានិមិត្តរូបនៃរបបរាជានិយម ?

នៅក្នុងសម័យសង្គមរាស្ត្រនិយម នៅពេលដែលព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម-សុរាម្រឹតស្តេចចូលទីវង្គត់ ក្រុមប្រឹក្សារាជសម្បត្តិបានជ្រើសរើសនរោត្តម-សីហនុ ឲ្យឡើងគ្រងរាជ្យសម្បត្តិ ។ ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំមិនទទួលតាមសំណើនេះ ដូច្នេះគេបានទូលសូមសម្តេចព្រះមហាក្សត្រីយានីព្រះកុសមៈ ស៊ីសុវត្ថិនារីរ័ត្ន ព្រះមហេសីព្រះករុណា ព្រះបាទសម្តេចព្រះនរោត្ត-សុរាម្រឹត និងជាព្រះមាតាទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំទុកព្រះអង្គជានិមិត្តរូបនៃចីរភាពស្ថិតស្ថិរចីរកាលនៃព្រះរាជបល្ល័ង្ក មកុដរាជ្យ និងរាជានិយម ។ គេគោរពនិងទុកព្រះអង្គជាព្រះមាតាជាតិ ជានិមិត្តរូបនៃរាជានិយម ហើយព្រះអង្គទ្រង់មិនកាន់អំណាចទេ ។

ដូច្នេះគួររាជរដ្ឋាភិបាលដែលមានសម្តេចហ៊ុន-សែនជាប្រមុខរាជរដ្ឋាភិបាល ព្រះមេត្តាទុលសម្តេចព្រះរាជអគ្គមហេសីនរោត្តម-មុនីនាថសីហនុ ជានិមិត្តរូបនៃរាជានិយមដូចក្នុងសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៦០ ទៅទល់នឹងឆ្នាំ១៩៦៩ មុនរដ្ឋប្រហារលោកលន់ ណល់-សិរិមតៈ ។ សម្តេចព្រះរាជអគ្គមហេសីបានបំរើជាតិមាតុភូមិ ប្រជារាស្ត្រដោយស្មោះស្ម័គ្រ សកម្មបំផុត និងមានប្រសិទ្ធិភាពបំផុត ។ ព្រះអង្គចេះរាក់ទាក់គួរសម ថ្លាក់ថ្លម ចេះគោរពព្រះសង្ឃ ហើយដែលប្រជារាស្ត្រគ្រប់រូបទាំងនៅក្នុងប្រទេស និងក្រៅប្រទេសគេពេញចិត្ត ។ មានតែផ្លូវនេះទេទើបថែរក្សាស្ថិរភាព និរន្តរភាពនៃរាជានិយមយើង ។ សម្តេចព្រះរាជអគ្គមហេសីមិនកាន់អំណាចអ្វីទាំងអស់ ហើយបំរើជាតិក្នុងវិស័យព្រះពុទ្ធសាសនា វិស័យឥស្លាមសាសនា វិស័យគ្រិះសាសនា និងក្នុងវិស័យវប្បធម៌ សង្គមកិច្ច មនុស្សធម៌ជួយកូនចៅកសាងសាលារៀន ផ្ទះពេទ្យ កូនស្ពាន ជីកស្រះ ។ល។

សម្តេចព្រះរាជអគ្គមហេសី គង់ជានិមិត្តរូបនៃរាជានិយមរហូតដល់មានក្រុមប្រឹក្សារាជសម្បត្តិអាចជ្រើសតាំងមហាក្សត្រថ្មី ។ ការជ្រើសរើសនេះ បើទាមទារឲ្យយល់ស្របគ្នាទាំង៩រូបជាឯកច្ឆន្ទទៅលើអង្គស្តេចណាមួយក៏ចេញមិនរួចទេ ។ សព្វថ្ងៃយើងពុំមានច្បាប់ទំលាប់អ្វីទេ គួរយើងយកភាគច្រើនពោលគឺ៥លើ៩ក្នុងចំណោម៩រូប ដោយសុខចិត្តធ្វើតាមច្បាប់លទ្ធិប្រជាធិបតេយ្យ ដោយមិនចាំបាច់បាន២ភាគ៣ ឬ១០០ភាគរយ ។ ការធ្វើបែបនេះយើងអាចចេញរួច ចៀសវាងមានគ្រោះថ្នាក់តទៅទៀត ។

តាំងពីគេសម្លាប់សង្គមរាស្ត្រនិយមមក គ្រោះថ្នាក់ធំ គ្រោះថ្នាក់មធ្យម គ្រោះថ្នាក់តូចមានការបាញ់កាប់សម្លាប់គ្នាមិនចេះចប់រហូតមកដល់សព្វថ្ងៃនេះ ។ គួរយើងប្រយ័ត្នប្រយ៉ែងកែកុនឲ្យបានត្រឹមត្រូវក្នុងជីវភាពជាតិយើង ដើម្បីជាឧត្តមប្រយោជន៍ កិត្តិស័ព្ទ កិត្តិនាមនៃមាតុភូមិកម្ពុជាយើង ដែលមានឈ្មោះថាមាតុភូមិអង្គរ

ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំយល់ឃើញថាគួរយើងដើរទៅតាមផ្លូវឲ្យបានស្រួល ឲ្យមានស្ថិរភាព ឲ្យមានអាយុយឺនយូរជាអតិបរមា ច្រើនសតវត្សរ៍តទៅមុខទៀតដល់កម្ពុជាមាតុភូមិជាទីស្នេហាសក្ការៈស្នេហាលើសជីវិតនៃយើងទាំងអស់គ្នា ។

សូមអរព្រះគុណ អរគុណជាអនេកប្បការ ។

(ព្រះហត្ថលេខា ៖ នរោត្តម-សីហនុ)

គិតទៅស្តេចសីហនុមានមហិច្ឆិតាធំធេងណាស់ ។ កាលសម័យសង្គ្រាមវៀតណាម ដោយព្រះអង្គចង់មានកេរ្តិ៍ឈ្មោះដូចហូ-ជីមិញ និងចង់ចូលរួមជ័យជំនះជាមួយប្រទេសយួននិងលាវ ទៅលើចក្រពត្តិប្រតិកិរិយាអាមេរិកាំងនៅក្នុងភូមិភាគឥណ្ឌូចិន ស្តេចនេះសុខចិត្តយកភ្លើងមកដុតផ្ទះឯងឆេះឲ្យយ៉ាងសន្ធោរសន្ធៅ រួចហាក់ទៅចូលរួមដៃជាមួយសត្រូវស្នូរពូជរបស់ជាតិ ។ ព្រះអង្គបានកៀងគរទ័ពពួកយួនយៀកកុង-យៀកណាមខាងជើង ឲ្យហាក់ចូលមកផ្តិលផ្តាច់អាយុជីវិតជនជាតិខ្លួនឯង និងបំផ្លាញទ្រព្យសម្បត្តិខ្មែរសឹងពាយអស់មួយនគរ ។ ទង្វើនេះក្រោយមកបានធ្វើឲ្យស្រុកខ្មែរក្លាយទៅជា <ទីលានពិឃាត> ឬក្លាយទៅជាស្ថាននរកលោកិយនៃសតវត្សរ៍ទី២០ ។

យោងតាមលោក Justin J. Corfield ក្នុងសៀវភៅ «ព្រះរាជវង្សានុវង្សនៃព្រះរាជាណាចក្រកម្ពុជា», បន្ទាប់ពីបានផ្តួលរំលំ<របបសាធារណរដ្ឋខ្មែរ>រួចហើយភ្លាម ស្តេចសីហនុបានឡើងធ្វើជា<ប្រមុខរដ្ឋ>នៃកម្ពុជាប្រជាធិបតេយ្យ ចាប់ពីថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៧៥ ។ លោក Corfield ពុំបាននិយាយថា នៅក្រោយពេលស្តេចសីហនុលាឈប់ពីតំណែងនាឆ្នាំ១៩៧៦ ព្រះអង្គត្រូវខ្មែរក្រហមដាក់<គុក>នៅក្នុងព្រះរាជវាំងទេ តែនិយាយថាព្រះអង្គត្រូវគេបង្ខំឲ្យ<ចូលនិវត្តន៍>ទៅវិញ (សូមអានទំព័រទី៩៨) ។

ការស្រេកឃ្លានចង់សោយរាជ្យឡើងវិញ បានបង្ខំឲ្យស្តេចសីហនុសុខចិត្តទម្លាក់ចោលការតស៊ូស្ទើរមួយទសវត្សឆ្នាំ៨០ប្រឆាំងនឹងអំពើឈ្លានពានរបស់យួន ហើយងាកទៅត្រូវរ៉ូវគ្នាជាមួយ<ក្រុមអាយ៉ងយួន> ។ សូមបញ្ជាក់ថា ពួកយួននេះគឺជាពួកយួនដដែល ដែលស្តេចសីហនុធ្លាប់បានអនុញ្ញាតឲ្យដីតាំងមូលដ្ឋាននៅតាមបណ្តោយព្រំដែនទិសខាងកើត និងជាពួកយួនដដែលដែលព្រះអង្គធ្លាប់បានពន្យះឲ្យចូលមកឈ្លានពានស្រុកខ្មែរកាលពីអំឡុងដើមឆ្នាំ៧០ ។

បន្ទាប់ពីបានឡើងសោយរាជ្យជាលើកទី២ (ក្បត់នឹងពាក្យសំដីរបស់ខ្លួនឯងកាលពីពេលដាក់រាជ្យថ្វាយព្រះបិតា ថាខ្លួននឹងមិនវិលត្រឡប់មកកាន់ព្រះរាជបល្លង្កវិញដាច់ខាត) ស្តេចសីហនុចាប់ផ្តើមគិតគូររៀបចំកន្លែងកន្លំទុកឲ្យ<កូននិងប្រពន្ធចុង>បន្តរាជ្យតទៅទៀត ។ បញ្ហានេះបានបណ្តាលឲ្យកើតមាន <សង្គ្រាមវាំង> រវាងម្តាយចុងនិងកូនដើម... ពោលគឺរវាងអ្នកម្នាងម៉ូនិចនិងទ្រង់រណឫទ្ធិ ដែលជាគូប្រកួតប្រជែងគ្នា ។

ដោយសារទ្រង់រណឫទ្ធិជា<នាយករដ្ឋមន្ត្រី> និងក្រោយមកជា<ប្រធានសភាជាតិ> ដែលជាសមាជិកយ៉ាងសំខាន់នៃក្រុមប្រឹក្សារាជសម្បត្តិ ទើបច្បាប់ជ្រើសរើសស្តេចស្នងរាជ្យ និងបញ្ហាស្តេចស្នងរាជ្យត្រូវតាំងស្ទេញរហូតមកទល់ពេលនេះ ។ ស្តេចសីហនុសំណូមពរធ្វើច្បាប់បោះឆ្នោតសម្លេង៥លើ៩ក្នុងចំណោមសមាជិកក្រុមប្រឹក្សារាជសម្បត្តិ៩នាក់ក្នុងរាជសារខាងលើគឺដើម្បីចៀសវាង<អំពើពហិការ>របស់ទ្រង់រណឫទ្ធិនេះឯង (!!) ។

ដើម្បីជាការដោះដូរគ្នាជាមួយលោកហ៊ុន-សែន ឲ្យឡើងធ្វើជានាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនីតិកាលទី៣ ស្តេចសីហនុចង់បានអ្នកម្នាងម៉ូនិចឡើងសោយរាជ្យបន្ត ដោយ<ធ្វើជា>ចេញរាជសារ<ទួញដំអូញ>ថា ព្រះចាស់ហើយមិនដឹងស្លាប់នៅថ្ងៃណាទេ !... ពុទ្ធោ !

ស្តេចសីហនុខំធ្វើការប្រៀបធៀបស្រុកខ្មែរ ទៅនឹងសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ (ប្រទេសកូរ៉េខាងជើង) (ព្រះអង្គមិនហ៊ានប្រៀបធៀបទៅនឹងប្រទៅនឹងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលគេលើកដំកល់ដំកើង<ហូ-ជីមិញ> ធ្វើជាបិតាអមត:របស់ជាតិយួនទេ) ថាជនជាតិកូរ៉េគេគោរពស្រឡាញ់លោកគីម-អ៊ិលសុងដូច<ព្រះ> សូម្បីងាប់ទៅហើយក៏គេនៅតែលើកដំកើងដែរ ។ ព្រះអង្គចង់ឲ្យប្រជារាស្ត្រខ្មែរលើកដំកើងប្រពន្ធចុងខ្លួន ដែលគ្មានឈាមជ័រជាស្តេចអ្វីបន្តិចសោះធ្វើជា<និមិត្តរូបនៃរបបរាជានិយម>ដាក់ពីលើខ្មោចម្តាយខ្លួនគឺព្រះមហាក្សត្រីយានីកុសម: ដែលព្រះអង្គបញ្ជាក់ថា ជានិមិត្តរូប<ចីរភាព និរន្តរភាព ស្ថិតស្ថិរចីរកាល>នៃរាជានិយម ។ បើព្រះមាតាជា<និមិត្តរូបចីរកាល>ទៅហើយ...ចុះប្រពន្ធចុងខ្លួនឯងធ្វើម្តេចនឹង<ចីរកាល>ពីលើម៉ែទៀតបានទៅ ? ។

ស្តេចសីហនុបំភ័យថា ៖ បើមិនព្រមធ្វើដូច្នោះទេ របបសាធារណរដ្ឋខ្មែរនឹងហាក់ត្រឡប់មកវិញពុំខាន ។ ដូច្នេះគឺមានតែ<ប្រពន្ធចុង>របស់ខ្លួននេះទេ ដែលអាចទប់ស្កាត់បានយ៉ាង<មានប្រសិទ្ធិភាពបំផុត> ។

ដើម្បីដឹងច្បាស់ពីអ្នកម្នាងម៉ូនិច-សីហនុ សូមអញ្ជើញអានប្រវត្តិរូបសង្ខេបដូចតទៅ ៖

**★ សរសេរដោយលោក Justin J. Corfield នៅក្នុងសៀវភៅ «Le Royal Family of Cambodia» p.106 ៖**

«ប្រពន្ធទី៦របស់សីហនុគឺ អ្នកម្នាង Monique Izzi ដែលជាកូនស្រីរបស់ François Izzi, ជនជាតិបារាំងកំណើតអ៊ីតាលី ជាមួយអ្នកស្រី Pomme Peang ។ អ្នកស្រី Pomme Peang កាលពីមុនរៀបការជាមួយវរ:សេនីយ៍ឯក អ៊ុំ-វីណារុធ (ស្លាប់កាលពីឆ្នាំ១៩៦៧) ។ អ្នកស្រី Pomme Peang ស្លាប់នៅថ្ងៃទី១ ខែមិនា ឆ្នាំ១៩៩១ នៅទីក្រុងប៉េកាំង ។ Monique Izzi កើតនៅថ្ងៃទី១៨ មិថុនា ឆ្នាំ១៩៣៦ និងធ្វើកិច្ចការយ៉ាងសកម្មក្នុងក្រុមកាកបាតក្រហម ចាប់ពីឆ្នាំ១៩៦០រហូតទល់ពេលរដ្ឋប្រហារឆ្នាំ១៩៧០, ធ្លាប់ធ្វើជាប្រធានកិត្តិយសកាកបាតក្រហមខ្មែរ ចាប់តាំងពីខែមិនាឆ្នាំ១៩៦១ ។ នាងបានរៀបការជាមួយសីហនុនៅថ្ងៃទី៥ មិនា ១៩៥៥ ហើយមានកូនពីរនាក់ ។ នាងបានត្រូវគេកាត់ទោសអវត្តមាន ធ្វើការជាទម្ងន់អស់មួយជីវិតជាមួយម្តាយរបស់នាង ដោយតុលាការគ្រាន់តែបង្ហាញឲ្យឃើញមួយជំនាន់សាធារណរដ្ឋខ្មែរ ។ នាងជាសមាជិកគណ:កម្មាធិការកណ្តាលនៃរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា (GRUNK) ចាប់ពីឆ្នាំ១៩៧៣ ។ នាងស្ថិតនៅជាមួយប្តីក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ហើយនៅក្នុងឆ្នាំ១៩៩០បានទៅរស់នៅជាមួយប្តីឯប្រទេសកូរ៉េខាងជើង» ។

**★ សរសេរដោយលោក Raoul M Jennar នៅក្នុងសៀវភៅ «Les Clés du Cambodge» p. 210 ៖**

«កើតនៅក្រុងភ្នំពេញ, ថ្ងៃទី១៨ មិថុនា ឆ្នាំ១៩៣៦, ឪពុកជាជនជាតិអ៊ីតាលី និងម្តាយ ជាជនជាតិចិនកាត់យួនឈ្មោះលោក Pomme ។ រៀនសូត្រមធ្យមសិក្សានៅវិទ្យាល័យ Descartes ។ រៀបការជាមួយនរោត្តម-សីហនុ ថ្ងៃទី៥ មិនា ឆ្នាំ១៩៥៥ ហើយមានងារជាអ្នកម្នាង ។ ការរួមសំបាច់គ្នានេះមានកូនពីរនាក់ ៖ នរោត្តម-សីហមុនី (កើតថ្ងៃទី១៥ ឧសភា ១៩៥៣) និងនរោត្តម-នរិន្ទ្រពង្ស (កើតថ្ងៃទី១៨ កញ្ញា ១៩៥៤) ។

បាននិរទេសខ្លួនទៅក្រុងប៉េកាំងជាមួយស្តេចសីហនុ ចាប់ពីខែមិនាឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ។ ត្រូវកាត់ទោសជាប់គុកមួយជីវិត ដោយតុលាការសឹកក្រុងភ្នំពេញ កាលពីថ្ងៃទី១៧ សីហា ឆ្នាំ១៩៧០ រួចហើយបាត់បង់សញ្ជាតិ ។

វិលត្រឡប់មកក្រុងភ្នំពេញវិញ ខែកញ្ញា ១៩៧៥ ។ ត្រូវខ្មែរក្រហមចាប់ដាក់គុកជាមួយស្តេចសីហនុ ពីខែមេសា១៩៧៦ ដល់ខែមករា១៩៧៩ ។

និរទេសទៅកាន់ក្រុងប៉េកាំងនិងក្រុងព្យុងយ៉ាង ជាមួយស្តេចសីហនុ ចាប់ពីខែមករា១៩៧៩ ដល់ខែវិច្ឆិកា១៩៩១ ។

ធ្វើសហប្រធានចលនាហ្វ៊ុនស៊ិនប៉ិច (ចាប់ពីខែសីហា១៩៨៩-កុម្ភ:១៩៩២) ។

បានឡើងឋាន:ជាព្រះរាជជាយា នៅថ្ងៃទី២០ កុម្ភ: ១៩៩២ ។

ឈ្នះបណ្តឹងក្នុងក្តីបរិហារកេរ្តិ៍ប្រឆាំងកាសែតបារាំង «ELLE» និងអ្នកកាសែតឈ្មោះ Alain Lebas កាលពីថ្ងៃទី១១ មិថុនា ១៩៩២ ជាទឹកប្រាក់ចំនួនមួយរយពាន់ត្រណោតបារាំង រួចហើយបានធ្វើអំណោយប្រាក់ទាំងអស់នោះទៅអង្គការក្រៅរដ្ឋាភិបាល «Handicap International» សំរាប់ជួយដល់ជនពិការ ។

បានឡើងឋាន:ជាព្រះមហាក្សត្រីកម្ពុជា (ថ្ងៃទី២៤ កញ្ញា ១៩៩៣)» ។

❑

បើយើងប្រៀបធៀបថ្ងៃរៀបការរវាងអ្នកម្នាងជាមួយស្តេចសីហនុ ដែលមាន

នៅក្នុងសៀវភៅរបស់ **Justin J Corfield** និងលោក **Raoul M Jennar** ជាមួយជីវប្រវត្តិរបស់អ្នកម្នាងចុះនៅក្នុង**website** របស់ស្ដេចសីហនុ, គេរកឃើញថាខុសគ្នា ។ នៅក្នុងសៀវភៅទាំងពីរសរសេរដូចគ្នាគឺ ថ្ងៃទី៥ ខែមិនា ឆ្នាំ១៩៥៥ ឯនៅក្នុង **website** គឺខែមេសា ឆ្នាំ១៩៥២ ។ បានសេចក្ដីថា អ្នកទាំងពីរមានកូនមុនរៀបការ ។ រឿងនេះមិនដឹងនរណាភរ ឬនរណានិយាយការពិតទេ (??) ។

តាមរយៈជីវប្រវត្តិខាងលើ យើងរកមិនឃើញអ្នកម្នាងម៉ូនិចមានឈាមជ័រតំណាតពីរាជវង្សអង្គណាសោះ ។ ដូច្នេះបើអ្នកម្នាងអាចក្លាយជា<ស្ដេចស្នងរាជ្យ>បាន នរណាៗក៏អាចក្លាយជា<ស្ដេចស្នងរាជ្យ>បានដែរ ដោយគេគ្រាន់តែនាំគ្នាហៅ និងនាំគ្នាកែ<រដ្ឋធម្មនុញ្ញ>តម្រូវតាមប៉ុណ្ណោះ (!!) ។ ការលើអ្នកម្នាងនេះ ជាអំពើប្រមាថមើលងាយលើព្រះមហាក្សត្រីយានីកុសមៈខ្លាំងណាស់ ដែលព្រះមហាក្សត្រីមានឈាមជ័រជាក្សត្រផង និងជាព្រះមាតារបស់ស្ដេចសីហនុថែមទៀត ។

ដោយធ្លាប់បានឮហ៊ុន-សែននិយាយថា ៖ «ខ្ញុំមិនចង់ធ្វើជាស្ដេចទេ..តែជាអ្នកបង្កើតស្ដេច!» យើងយល់ថា «វាសមមុខពួករាជានិយម»ណាស់ ដែលមានស្ដេចឪយ៉ាងដូច្នេះ ក៏ប៉ុន្តែយើងនៅតែឆ្ងល់ថា ៖ តើហេតុអ្វីបានមានពួករាជានិយមខ្លះនាំគ្នាគាំទ្រស្ដេចកូន ហើយឈ្លោះនឹងស្ដេចឪ... រួចមានពួករាជានិយមខ្លះទៀតគាំទ្រស្ដេចឪ ហើយប្រឆាំងនឹងស្ដេចម៉ែ ជាពិសេសមានពួករាជានិយមខ្លះទៀតនោះដើរនិយាយថា ៖ «កុំច្រឡំអីុយ...រាជានិយមហ្វ៊ុនស៊ិនប៉ិចផ្សេង...ហើយរាជានិយមព្រះកូណាផ្សឹង! » ។

រួចយើងក៏សុំសួរទៀតថា ៖ ចុះមានរាជានិយមម៉ូនិចដែរឬទេ ?...

?!?! ៚